មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយ ជា អ៊ឹម ភេទស្រី អាយុ៦៩ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ "កងចល័ត"
## សព្វថ្ងៃរស់នៅភូមិឈើទាលជ្រុំ ឃុំ ថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ
## ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២
## សម្ភាសន៍ដោយៈ អេង កុកថាយ
## ០១:០១:០១
## ៣០ទំព័រ

ថាយ: មីងឈ្មោះអីដែរ បាទ?

អ៊ឹម : ឈ្មោះ ជា អ៊ឹម ។

ថាយ : ឈ្មោះ ជា អ៊ឹម ចុះឈ្មោះបដិវត្តន៍ឈ្មោះអី?

អ៊ឹម : ឈ្មោះតែមួយហ្នឹងឯង ។

ថាយ : អាយុប៉ុន្មានហើយឥឡូវ?

អ៊ឹម : អាយុ៦៩ ។

ថាយ : ចុះប្តីមីងឈ្មោះអី ប្តីមីងគ្រួសារ?

អ៊ឹម : គ្រួសារខ្ញុំស្លាប់បាត់ហើយ ។

ថាយ : ស្លាប់បាត់ហើយ ឆ្នាំប៉ុន្មានដែរ?

អ៊ឹម : ស្លាប់ឆ្នាំប៉ុន្មានទេ ៧ឆ្នាំហើយ គាត់ឈឺស្លាប់ ។

ថាយ: ៧ឆ្នាំគាត់ឈឺស្លាប់?

អ៊ឹម: ចាំ!

ថាយ : កាលមុនសម័យខ្មែរក្រហមមីងមានស្រុកកំណើតនៅឯណា?

អ៊ឹម : មានស្រុកកំណើតនៅខេត្តតាកែវ ។

ថាយ : ខេត្តតាកែវ ភូមិស្រុកអ៊ីដែរ?

អ៊ឹម : ស្រុកនៃត្រាំកក់ ។

ថាយ: ស្រុកត្រាំកក់ ខេត្តតាកែវ?

អ៊ឹម: ចាំ!

ថាយ : ចុះមីងចូលបដិវត្តន៍នៅឆ្នាំប៉ុន្មាន ដែរ?

អ៊ឹម : ឆ្នាំប៉ុន្មានទេខ្ញុំភ្លេចបាត់ហើយ ខ្ញុំអត់ចាំឆ្នាំដែរ ។

ថាយ ៖ អត់ចាំឆ្នាំទេ ហើយគ្រួសារមីងចូលឆ្នាំណាដែរ?

អ៊ុម ៖ កាលចូលហ្នឹងកាលណាទេ មិនដឹងឆ្នាំប៉ុន្មានទេ?

ថាយ ៖ តែអាចរៀបរាប់ចូលកាលជំនាន់ហ្នឹងមានអីខ្លះ
យ៉ាងម៉េចទៀតទៅព្រឹត្តិកាលនៅក្នុងស្រុកហ្នឹង?

អ៊ុម ៖ កាលឆ្នាំចូលហ្នឹង គ្រាន់តែចូលចឹងហើយក៏វាយគ្នានូវអង្គតាសោម ដំហើយគេចូលរហូតទៅ ចូលក្នុងរហូតដល់គេវាយបែកអស់ចឹងទៅគ្មានធ្វើអី មានតែគេឲ្យជីកប្រឡាយ លើកទំនប់ អីហ្នឹង ។

ថាយ ៖ បាទ! ចូលហ្នឹងក្រោយ លន់ ណល់ធ្វើរដ្ឋប្រហារ?

អ៊ុម ៖ ហ្នឹងហើយក្រោយ ។

ថាយ៖ ក្រោយប្រហែលប៉ុន្មានឆ្នាំ?

អ៊ុម៖ ហ៊ឺ! មិនដឹងប៉ុន្មានទេ ។

ថាយ ៖ ក្រោយ ឥឡូវយើងស្ទង់មើលលន់ ណល់ ឬឆ្នាំ៧០ តើរដ្ឋប្រហារខ្ទង់ប៉ុន្មាន ហើយបាន យើងចូលហើយយើងចូលបានប្រហែលជាប៉ុន្មានបានបែកភ្នំពេញហ្នឹងបានត្រូវគេជម្លៀស អីចឹង ។

អ៊ុម៖ ហ៊ឺ! ដឹងឆ្នាំប៉ុន្មានទេ ខ្ញុំភ្លេចដែរហើយ ។

ថាយ៖ បាទ!

អ៊ុម ៖ មើសមានខ្មែរក្រហមនៅឆ្នាំប៉ុន្មានទេ៧០ ។

ថាយ ៖ បាទ! ៧០?

អ៊ុម ៖ ៧០អើឆ្នាំ៧៥ ។

ថាយ៖ ៧៥?

អ៊ុម៖ ចាស់ ។

ថាយ ៖ ឆ្នាំ៧៥ យើងចូល?

អ៊ុម ៖ ឆ្នាំ៧៥ វាយបែកហើយ គេចូលទាំងអស់គ្នាតែម្តង នៅឃុំលីបូល ព្រោះអីវាមាន ផ្សារ ទាំង សងខាងចេះហ៎ណា ដល់គេវាយបែកអង្គក្រសោមរណសិរ្ស ចឹងទៅរត់ មកនៅឯ លើហ្នឹងណា គេចូលរហូត ។

ថាយ ៖ រត់មកនៅឯណា?

អ៊ុម ៖ មកនៅវៀងចា ។

ថាយ ៖ វៀងចា ស្រុកអី?

អ៊ុម ៖ ស្រុកនែ៎ត្រាំកក់ដូចគ្នា ។

ថាយ៖ ត្រាំកក់ដូចគ្នា?

អ៊ុម៖ ចាស់! ឃុំដើមទន ។

ថាយ ៖ តើមីងចូលនូវពេលដែលចូលគេមានឲ្យមីងធ្វើអីគេខ្លះ?

អ៊ុម ៖ មានឲ្យធ្វើអី ឲ្យតែជីកប្រឡាយ លើកទំនប់ ។

ថាយ ៖ ជីកប្រឡាយ លើកទំនប់ធម្មតា ។

អ៊ុម៖ ចាស់!

ថាយ៖ បាទៗ! ចុះមីងរៀបការនៅឆ្នាំប៉ុន្មានដែរ?

អ៊ុម ៖ ខ្ញុំរៀបការតាំងពីឆ្នាំ៧០ ។

ថាយ៖ ៧០ ។

អ៊ុម៖ ចា៎!

ថាយ ៖ អញ្ចឹងចូលបដិវត្តន៍មុនរៀបការ?

អ៊ុម៖ ក្រោយ ។

ថាយ៖ ក្រោយ?

អ៊ុម ៖ អូសរៀបការមុនចូល ។

ថាយ៖ រៀបការមុនចូល?

អ៊ុម៖ ចា៎!

ថាយ ៖ មុនចូលចុះគ្រួសារមីងមានចូលទេ?

អ៊ុម ៖ កាលហ្នឹងចុះគោះចូល គឺចូលទាំងអស់គ្នាហើយ ។

ថាយ ៖ អ៎! ចឹងមិនមែនចូលបំរើបដិវត្តន៍ដូចគេទេ?

អ៊ុម ៖ អត់ទេប្រជាជនធម្មតាទេ ។

ថាយ ៖ ប្រជាជនធម្មតា?

អ៊ុម ៖ ចាស់! ប៉ុនកាលខ្ញុំចូលហ្នឹងខ្ញុំបានកូន២ហ៎ណា ។

ថាយ៖ បានកូន២ហើយ?

អ៊ុម៖ ចា៎!

ថាយ ៖ គេឲ្យនៅត្រាំកក់ ។ ហើយអើក្រោយពីនៅត្រាំកក់លើកទំនប់ លើកប្រឡាយ ហើយគេឲ្យធ្វើអីទៀត ទៅណា ទៅណីទៀត?

អ៊ុម ៖ គ្មានទៅណា មានតែនៅស្ទូងដក ។

ថាយ ៖ ស្គួនដក! នៅតែមួយស្រុកហ្នឹង?

អ៊ឹម ៖ ស្រុកហ្នឹងខ្លះមនុស្ស មឿនចាករត់យូរមកនៅមួយចាកហ្នឹង ។

ថាយ ៖ មឿនចាកហ្នឹងនៅណាចេះ?

អ៊ឹម ៖ នៅឃុំជ័យទង ស្រុកត្រាំកក់ ដូចគ្នា ។

ថាយ៖ ដដែល?

អ៊ឹម៖ ចា៎! ស្រុកដូចគ្នាតែនៅឃុំខុសគ្នា ។

ថាយ ៖ ជួយរៀបរាប់ពីបទពិសោធន៍នៅក្នុងសម័យខ្មែរក្រហមរបស់មីងយ៉ាងម៉េចខ្លះគេឲ្យ ធ្វើការយ៉ាប់ ពិបាក សប្បាយ កម្សត់ គ្រេកអរ ម៉េច?

អ៊ឹម ៖ ដល់ពេលនោះបានគេឲ្យលើកទំនប់ ជីកប្រឡាយនឹងហើយ បានគេឲ្យទៅលើកទំនប់ស្ទឹងគេពងបែកហ៎ ។

ថាយ៖ ពងបែក?

អ៊ឹម៖ ស្គាល់ពងបែកហ៎ ។

ថាយ ៖ គួសបែកនៅតាកែវ ហ្នឹងត្រាំកក់?

អ៊ឹម ៖ នៅខាងព្រំប្រទល់កំពង់ស្ពឺ អុះកំពង់ស្ពឺអីកំពត ។

ថាយ ៖ អ៊ូ! ឥឡូវនៅដើរដដែលទេ ទំនប់ហ្នឹង?

អ៊ឹម ៖ ទំនប់ហ្នឹងមិនដឹងម៉េចខ្ញុំមិនដែលដឹងដែរ ។

ថាយ ៖ ឆ្នាំមុនមានទំនប់មួយនៅជិតអង្គក្រសោមអីទេ ទំនប់មួយបាក់ទៅ?

អ៊ឹម ៖ ចុះពីអង្គក្រសោមទៅ ទៅជិតព្រះអណ្ដើក ។

ថាយ ៖ បាទៗ! គេឲ្យទៅណោះ?

អ៊ឹម ៖ គេឲ្យទៅលើកទំនប់នៅហ្នឹងទៀត ហ្នឹងគេឲ្យតែប្រុសៗទៅទេណា ស្រីបើថាលីវបានគេឲ្យទៅ បើមានកូនមានអីគេអត់ឲ្យទៅទេ ឲ្យទៅតែប្រុសៗនៅលីវៗទេ ។

ថាយ ៖ ចុះគេអត់ឲ្យយើងទៅទេ?

អ៊ឹម ៖ អត់ទេ ឲ្យនៅធ្វើការនៅភូមិ ព្រោះអីកូនតូច ។

ថាយ៖ បាទៗ!

អ៊ឹម៖ អីកម្លាំងទីពីរគេនោះគេឲ្យនៅធ្វើស្រែឯភូមិនោះណាលើកទំនប់ឯភូមិណោះ បើប្ដីទៅហើយ ២-៣ខែមកផ្ទះម្ដង មកបានតែមួយថ្ងៃនឹងស្អែកឡើងទៅវិញ ហើយអត់ដែល បានមកផ្ទះយូរទេ ។

ថាយ៖ បាទ!

អ៊ឹមៈ នឹងខ្ញុំនិយាយពីរឿងខ្លួនខ្ញុំហ្នឹងណា ។

ថាយ ៖ បាទ!

អ៊ឹមៈ ចាស់! ដឹលើកទំនប់នឹងហើយថាខ្ញុំធ្វើការនោះវាហួយនិស្ស័យ ខ្ញុំពិបាកណាស់ គេឲ្យរែកដីលេខមួយ ឲ្យបាចស្រូវគេលាយផេះហើយបាចស្រូវនោះពេញៗមួយដៃ ឲ្យតែគេប្រើម៉េច ក៏អត់ហ៊ានប្រកែកនឹងគេដែរធ្វើតាមគេទាំងអស់ចុះខ្លាចខុសវិន័យគេនោះ ។

ថាយ ៖ រួចយកអីទៅលាយធ្វើជីខ្លះ?

អ៊ឹម ៖ លាមកមនុស្សយើងនឹង ។

ថាយ ៖ យកទៅលាយជាមួយអី?

អ៊ឹម ៖ ជាមួយនឹងផេះហើយបាចស្រូវ ។

ថាយ ៖ ផេះចេះៗអីនឹងហ្ន៎?

អ៊ឹមៈ នឹងហើយផេះយើង ចង្ក្រានយើងនឹងយើងបំពួកផេះអង្កាមអីហ្នឹងណា ហើយយកទៅលាយជាមួយនេះនឹងគេយកទៅបាចស្រូវ រែកដើររែកតាមបង្គន់គ្រប់ផ្ទះចឹង ទៅរួចយកទៅ ដាក់មានឃ្លាំង ប្ញរណ្តៅធំចឹងទៅដឹតែពេលប្រមូលរួចអស់ចឹង ទៅគេថាហ្នឹងដាក់យកទៅលាយហើយរែកយកទៅបាចស្រូវដឹហើយខ្ញុំចេះតែធ្វើហើយឲ្យតែគេប្រើធ្វើអីក៏ធ្វើដែរ ។ ដល់គេឲ្យធ្វើអានឹងអស់ចិត្តគេអស់កន្លែងធ្វើទៅ គេឲ្យទៅកន្លែងស្ទូងទៀតហើយ ទៅស្ទូងស្រែប្រាំង ស្រែអីគេឯណាឯណីទៀតហើយ ថាឲ្យតែគេប្រើអត់មានប្រកែកទេ ធ្វើអីក៏ទៅដែរហើយ ចេះតែទៅ ហើយដល់តែពេលនេះបានគេចខ្លួនកាលយួនចូល គេចខ្លួនមកនៅតាមព្រំដែន មកនៅតាមព្រំដែននឹង ហ្ន៎យវេទនាណាស់អត់បាយក្រហាយទឹកគ្មានអីស៊ីទេ ប្តីក៏ឈឺ កូនក៏ឈឺ ។

ថាយ ៖ បាទ! មកនៅតាមព្រំដែននឹងចំណុចកន្លែងណា?

អ៊ឹម ៖ ចំណុចនែ៎ម៉ាឡៃកាលនឹងសុទ្ធតែព្រៃ ។

ថាយ ៖ បាទ!អញ្ចឹងកាលជម្លៀសមកមីងរត់ជាមួយខាងខ្មែរក្រហមមក ។

អ៊ឹម ៖ ចាស់!

ថាយ ៖ បាទ!

អ៊ឹម ៖ ដឹមកនៅតាមព្រំដែនព្រៃអស់ទាស់ហើយ គ្មានឃើញពន្លឺព្រះអាទិត្យអីទេមិនដឹងយប់មិនដឹងថ្ងៃ ទេដល់ហើយវាចាញ់ហ្នឹងណាគ្រុនប្តីខ្ញុំសន្ធមបាត់នែ៎អត់មានដឹងខ្លួនរហូត ដល់ចូលមកដល់ដីថៃ បានដឹងខ្លួន ហើយនោះក៏ឈឺ សុទ្ធតែសន្ធម ទាំងអស់ អាកូន២ ។

ថាយ ៖ កូនប៉ុន្មានដល់ពេលនឹង?

អ៊ុម ៖ កូនខ្ញុំបីនាក់ហើយ ។

ថាយ ៖ ធំៗ អស់ហើយ?

អ៊ុម ៖ កូនខ្ញុំអាមួយនោះ៧ឆ្នាំ មីមួយនោះ៥ឆ្នាំ មីមួយនោះទឹមតែ១០ខែ ។

ថាយ ៖ ហើយម៉េចទៀត?

អ៊ុម ៖ ដល់ពេលមកដល់ដីថៃអត់ដីឯខ្លួនទៀតហើយអាកូននោះក៏ឈឺ ឪក៏ឈឺខ្ញុំរែកអំព្រែក នៅកករហើយមានអាស្ពាយពីក្រោយទៀត មានអាដាក់កូនពីមុខចេះទៀត ចុះបើប្តីឈឺ ហើយមានណាជួយយើង ខ្លួនទីពីឯខ្លួនហ៎នឹង កាលប្តីបានគាត់រែក ហើយខ្ញុំមើល តែកូនស្ពាយតែអង្ករ ទែអង្ករដាក់សងខាងហីកូនពីមុខចឹងទៅអាតូច អាធំៗនឹងដើរទៅ សាក់កាដូរខោអាវពីក្រោយ ។

ថាយ ៖ មានអីទៀតទេជាតិទ្រព្យ?

អ៊ុម ៖ មានអីមានតែប៉ុណ្ណឹង បានតែយកមួយរូចខ្លួន បានតែមួយស្បៀកពាក់ហើយ នឹងអង្ករតិចតួចហូបតាមផ្លូវ នឹងបានទិញប្តីខ្ញុំគាស់ធ្មេញ ធ្មេញគាត់ដាក់ធ្មេញមាស គាស់ធ្មេញយកទៅលក់បានលុយទិញអង្ករឲ្យកូនស៊ី បើអត់មានអង្ករឲ្យកូនស៊ី យកទៅលក់ឲ្យថៃ៥ជី លក់បានតែ១០០០បាតទេ ។

ថាយ ៖ ពេលទៅដល់សំឡូតហើយបានគាស់លក់ហ៎?

អ៊ុម ៖ អត់ទេទៅនេះ ស្ទីទេកាលនឹងគេមិនមែនហៅម៉ាឡៃទេណា គេហៅចក្រី អូរចក្រី អូរអន្ទកអូរល្ហុងអីចឹងទៅណាកាលនឹងសុទ្ធតែព្រៃតែឥឡូវវាលអស់ហើយព្រុកគេថាវាលអស់ហើយដល់ហើយគេថាហ៎កយួនបុកមកដល់ហើយរត់ចូលដីថៃ បានខ្ញុំទៅនៅដីថៃទាល់តែកូនខ្ញុំក្រមុំកម្លោះ បានៗចេញវិញ ។

ថាយ ៖ អ៊ូ! ទៅជំរុំអី?

អ៊ុម ៖ មុនដំបូងចូលស្រះកែវ ចេញពីស្រះកែវ គេយកមកដាក់នៅខោវដារ ។

ថាយ ៖ បាទ! អត់បានចេញទៅក្រៅនឹងគេ ។

អ៊ុម ៖ អត់ធ្វើតេះអត់ជាប់ ទាល់តែមកវិញមកទៅបានមួយឆ្នាំបានម៉ែខ្ញុំនឹងក៏យកមកនៅនេះមក ។

ថាយ ៖ នៅស្រុកណានៅត្រាំកក់នឹង?

អ៊ុម ៖ នៅត្រាំកក់ ពិននៅឃុំលីបូល ។

ថាយ ៖ អ៊ូ! លីបូល?

អ៊ុម ៖ ចាស់! ពិនស្រុកត្រាំកក់ដូចគ្នាទេណា គ្រាន់តែឃុំខុសគ្នា ។

ថាយ ៖ បាទ! ចុះចេញពីជំរុំមកខ្វង់ឆ្នាំប៉ុន្មាន?

អ៊ីម ៖ ចេញពីជំរុំមកឆ្នាំប៉ុន្មានទេ៨០ប៉ុន្មានទេ ដូចជា៨៣ចឹងអី?

ថាយ ៖ ចេញពីជំរុំហ៎?

អ៊ីម ៖ ៨៤អ៊ូ! ៨៤ អី៨៥ទេនែ៎ កាលអ៊ុនគាត់ចូលមក ។

ថាយ ៖ កាលអ៊ុនគាត់ចូលមក?

អ៊ីម ៖ ចាស់!

ថាយ ៖ កាលអ៊ុនគាត់ ចូលមក៩១-៩២-៩៣?

អ៊ីម ៖ កាលនឹងដឹង ។

ថាយ ៖ អត់ទេឥឡូវកាលចេញនឹងកាលអ៊ុគាត់មកហើយ?

អ៊ីម ៖ ចាស់! គ្រាន់តែដឹងថាអ៊ុនគាត់ចូលស្រុកហើយគេបញ្ជូនមកនៅស្រុកកន្លែង ភូមិណា ឃុំណា ឲ្យមកនៅតាមភូមិ តាមឃុំវិញ ។

ថាយ ៖ អ៊ូ! គេបញ្ជូនមីងមកនៅភូមិណា ឃុំណា?

អ៊ីម ៖ គេបញ្ជូនមកកន្លែងភូមិ ឃុំខ្ញុំនឹងឯង ។

ថាយ ៖ ភូមិណា?

អ៊ីម ៖ ភូមិនែ៎ ។

ថាយ ៖ នៅស្រុកត្រាំកក់នឹង?

អ៊ីម ៖ នៅស្រុកត្រាំកក់នឹងណា ប៉ុន្តែឃុំលីបូល ភូមិត្រពាំងត្រាច មកនៅហ្នឹងធ្វើស្រែបានមួយវស្សាហ្នឹងក៏ម៉ែទៅខ្ញុំយកមកខ្ញុំមកនៅហ្នឹងជាមួយគាត់ទៅ ។

ថាយ ៖ មកនៅណេះ មកនៅអន្លង់វែងនេះ?

អ៊ីម ៖ ចាស់! ចុះនៅនោះអត់មានដីធ្វើស្រែ ។

ថាយ ៖ ចឹងនៅនោះបានមួយឆ្នាំបានមកណេះ?

អ៊ីម ៖ នៅបានមួយវស្សាទេអត់បានមួយឆ្នាំទេ ។

ថាយ ៖ ហើយមីងបោះឆ្នោតនៅណា?

អ៊ីម ៖ បោះឆ្នោតនៅនេះ ។

ថាយ ៖ នៅណេះ នៅអន្លង់វែងនេះ?

អ៊ីម ៖ នៅអន្លង់វែង ។

ថាយ ៖ នៅផ្ទះមីងតែម្តង?

អ៊ីម ៖ កាលពីទីមមកដល់នៅជិតផ្ទះតាម៉ុក ។

ថាយ ៖ អ៊ូ! ជិតផ្ទះតាម៉ុក?

អ៊ុម ៖ នៅជិតស្ពាន ។

ថាយ ៖ បាទ!

អ៊ុម ៖ ស្ពានតាម៉ុក ។

ថាយ ៖ ចុះម្ដាយមីង អើម៉ែមីងគាត់រស់នៅហ្នឹង?

អ៊ុម ៖ នៅឥឡូវគាត់នូវ៨០០ ។

ថាយ ៖ អូ! កាលពីមុនដែលគាត់ទៅយកមីងនឹងគាត់រស់នៅអន្លង់វែងនឹង?

អ៊ុម ៖ ចា៎! គាត់ទើបមករស់នៅដែរហ្នឹង គាត់ទឹមមកពីណាអណ្ដែងមុតអីទេ ខ្ញុំមិនសូវដឹងដែរ ហើយ ដល់គាត់មកនៅនេះថាមានដីច្រើនអីចឹងទៅណា ហើយពុថាខ្ញុំចេញពីជំរុំមក អត់មានដីធ្វើស្រែក៏គាត់ឲ្យគេយកមកឲ្យ គេយកមកក៏នៅជាមួយគាត់រហូតមក ពេលកូនខ្ញុំបែកមានប្ដីទៅបានបែកពីគាត់មកនៅភូមិនេះ ។

ថាយ ៖ នៅភូមិនេះ?

អ៊ុម ៖ ចា៎! ថានេះនៅជាមួយគាត់ ថាកូនខ្ញុំគេបានប្ដីនៅភូមិនេះគេមកតាមកូនខ្ញុំទៅណា ។

ថាយ ៖ មកភូមិនេះប៉ុន្មានឆ្នាំហើយ?

អ៊ុម ៖ ហ៎! ប៉ុន្មានឆ្នាំហើយទេ យូរដែរហើយ ពូយើងមកនៅភូមិនេះប៉ុន្មានឆ្នាំហើយ ។

អ្នកភូមិ៖ ១០ឆ្នាំជាងហើយ ។

អ៊ុម៖ ជាង១០តែមិនដឹងជាងប៉ុន្មានទេ ។

ថាយ ៖ ចុះពេលម្ដាយរបស់មីងយកមីងមកនៅ មកនឹងមកទាំងគ្រួសារ?

អ៊ុម ៖ មកទាំងគ្រួសារ ។

ថាយ ៖ មកទាំងប្ដីទាំងកូន?

អ៊ុម ៖ ចា៎!

ថាយ ៖ អត់ខ្លាចទេ ចូលមកនៅនេះបានន័យថា នូវក្នុងរបបខ្មែរក្រហម?

អ៊ុម ៖ អត់ខ្លាចទេ ពេលមកដល់អត់អីដែរ ។

ថាយ ៖ អត់អីដែរ?

អ៊ុម ៖ ចា៎!

ថាយ ៖ ចេះតែឆ្លងមកផុតតាមព្រំប្រទល់ខ្សែត្រៀមគេចូលមក?

អ៊ុម ៖ ចា៎! ដូចអត់អី អត់មានបញ្ហាអីផង ដើរហូតមកដល់អន្លង់វែងនឹងបណ្ដោយ ។

ថាយ ៖ ចុះជិះឡានមកក៏ដើរមក?

អ៊ុម ៖ មកពីនោះមកឡាន ដល់ចុះពីឡានមកម៉ូតូ ចុះពីម៉ូតូមកឡានទៀត ឡានគេមកដល់ ។

ថាយ ៖ ឡានទើបមកដល់?

អ៊ឹម ៖ ចា៎!

ថាយ ៖ ឡានណាទាន់ហាន?

អ៊ឹម ៖ ឡានតាម៉ុក តាំងពីគោកស្រុកមកជិះឡានតាម៉ុក ហើយមកពីនោះមកជិះឡានឈ្នួល មកដល់បូរិនបានជិះម៉ូតូ មកដល់គោកស្រុកនឹង ។

ថាយ ៖ ពីគោកស្រុកមកនេះជិះឡានគេមក?

អ៊ឹម ៖ ចា៎!

ថាយ ៖ ជិះប៉ុន្មានថ្ងៃ ជិះពីសៀមរាបមកដែរ?

អ៊ឹម ៖ ដើរតាមសៀមរាបពីខាងនោះខាងបាត់ដំបង ។

ថាយ ៖ បាត់ដំបង?

អ៊ឹម ៖ ចា៎! មកពីនោះមកដេកផ្លូវតែមួយយប់ ។

ថាយ ៖ មកដល់ណេះ?

អ៊ឹម ៖ មកដល់គោកស្រុក ដឹមកដល់គោកស្រុកដេកផ្លូវដេកគោកស្រុកមានឡានគេចេញមក ដេកបីយប់ចាំឡានគេមកដល់ណេះ នៅចាំឡានគេ បើសិនជាមករហូតមកដេកផ្លូវតែមួយយប់នឹងដល់បាត់ ។

ថាយ ៖ ចុះមកដល់មីងធ្វើអីខ្លះ មកដល់ដំបូង?

អ៊ឹម ៖ មកដល់គ្មានធ្វើអី មកដល់ប្អូនខ្ញុំគេភ្ជួររាស់អីហើយអស់ មកដល់គេឲ្យដាំស្រូវនឹងទៅ ។

ថាយ ៖ ហើយយ៉ាងម៉េចទៀត ដូចថាមីងអាចរៀបរាប់ពីជីវភាពរបស់មីងនៅក្នុងតំបន់អន្លង់វែងក្រោមការដឹកនាំរបស់តាម៉ុ?

អ៊ឹម ៖ មកដល់ដូចអត់អី ដូចថាមកដល់ជីវភាពក្រុមគ្រួសារខ្ញុំប្អូនខ្ញុំម៉ែខ្ញុំនឹងធូរធាដែរនឹងណា គាត់ចិញ្ចឹមមួយវស្សានឹង មួយឆ្នាំទម្រាំតែស្រូវទាន់ ទម្រាំស្រូវទុំគាត់ចិញ្ចឹមរហូតដែរ ដល់ពេលបានទាន់ស្រូវនឹងបានផលមកខ្ញុំបានជាង២០បាវ ។

ថាយ ៖ បាទ!

អ៊ឹម ៖ ជាង២០បាវរួចខ្លួនហើយណា ។

ថាយ ៖ ដីប៉ុន្មាន១អារ?

អ៊ឹម ៖ នែ៎! ធ្វើចូកគ្នាដល់ហើយពេលបានផលគេចែកចំណែក ។

ថាយ ៖ ធ្វើចូលជាមួយម្តាយបងប្អូនមីងនឹង ។

អ៊ីមៈ ចា៎! ដល់គេចែកចំណែកបានជាង២០ បាវម្នាក់ក៏ធ្មើកន្លែង ធ្វើអីដាក់ហើយ មិនទាន់បានហូបស្រូវនឹងទេ ។ គេថាហ៎ ទាហានបុកមកទៀតហើយ រត់ទៀតហើយរត់ទៅរហូតទៅដល់ភ្នំតាចក់រត់ទៅនឹងឯង ។

ថាយ : ឡើងលើភ្នំដងរែកមិនទាន់ឡើងទេ?

អ៊ីម : ចា៎!ឡើងលើភ្នំដងរែក ចុះពីភ្នំដងរែកឡើងលើភ្នំតាចក់ទៀត ទៅហួសដងរែកនោះទៀតដល់ពេលនេះមកវិញ អាផ្ទះភ្លើងឆេះអស់អាលីង គេដុតចោលអស់ អាភ្លើងឆេះស្រូវអស់ អាលីង អាផ្ទះក៏ឆេះអស់អាលីង ។

ថាយ : ហើយម៉េចអត់យកស្រូវទៅខ្លះ?

អ៊ីម : មានស្អីដឹក ឡានគេដឹកសម្ភារៈរបស់គេ ប្រជាជនរែកដើរ ស្រូវនៅចោលផ្ទះទាំងអស់ ដុតភ្លើងឆេះអស់ទៅ មកវិញអត់អីហូប តាម៉ុកនឹងចិញ្ចឹមប្រជាជនដែលរត់ទៅតាមផ្លូវនឹង ទាំងប៉ុន្មាន តាម៉ុកនឹងទិញអង្ករចែកទៅណា ។

ថាយ : បាទ!

អ៊ីម : តាមមាត់ចឹងទៅមាត់ច្រើនចែកតាមច្រើនចឹងទៅណា ។

ថាយ : បាទ!

អ៊ីម : ចែករហូតទាល់តែយើងធ្វើស្រែបានវិញនឹងបានផ្អាក ។

ថាយ : ចុះពេលមុនយើងរត់ទៅយើងធ្វើស្រែចិញ្ចឹមខ្លួនឯងតាមតាម៉ុកចាត់ចែក ។

អ៊ីម : អត់ទេ] ពេលយើងធ្វើបានខ្លួនយើង ។

ថាយ : គេចាយលុយអីមីង?

អ៊ីម : ចាយលុយថៃ ។

ថាយ : លុយបាតចុះត្រូវការទិញឥវ៉ាឥវ៉ាន់អីខាងតាម៉ុកគេមានលក់ដែរ ខាងពាណិជ្ជគេ គេលក់អីខ្លះពាណិជ្ជគេ?

អ៊ីម : គេមានលក់តាំងពីឆ្នាំ តាំងពីចាន តាំងពីផ្ទិល តាំងពីសាប៊ូ ប៉ោកខោរអាវអីថាម៉ាចប់ចុះពាណិជ្ជគេនោះ គេមានគ្រប់មុខទាំងអស់យកពីថៃមក ។

ថាយ : ចុះយើងលក់ខ្លួនឯងគេឲ្យលក់ដែរ?

អ៊ីម : អត់មានពីណាគេលក់ផង អើបើជាគេចង់រកស៊ីលក់គេបិទស្រារបិទអីលក់គេចេះលក់បានទៅណា ។ហើយខ្ញុំមិដឹងរកស៊ីអីគេបើស្រារមិនចេះបិទផង ។

ថាយ : អ្នកខ្លះគេទៅដឹកគោពីស្ទោងពីអីយកមកលក់ឲ្យថៃមានដែរ?

អ៊ីម : ពិននៅកន្លែងខ្ញុំនៅដូចជាអត់ទេ ។

ថាយ ៖ អត់ហ៊ានព្រោះអីនៅជិតផ្ទះតាម៉ុកពេក?

អ៊ីម ៖ ដូចជាគ្មានអ្នកណារកស៊ីចឹងៗផងកាលនឹង ។

ថាយ ៖ មានអ្នកនៅភូមិមីងនៅភូមិថ្នាប ខ្ញុំជួបទៅទៅថាលំដែរតើលួចលក់?

អ៊ីម ៖ នឹងគេផ្សេងតែបើថានៅកន្លែងខ្ញុំនឹង គឺអត់មានទេ ចុះជាប់ផ្ទះតាម៉ុក ។

ថាយ ៖ នឹងហើយ?

អ៊ីម ៖ ណាហ៊ានរកស៊ីចឹងៗនោះ ។

ថាយ ៖ មីងខស្សាហ៍បានជួបតាម៉ុកទេ?

អ៊ីម ៖ ខ្ញុំជួបតែញឹកនឹង ។

ថាយ ៖ អ្ហ៊ូ!

អ៊ីម ៖ ពិនតាម៉ុកសម្តីអាក្រក់ណាស់ ។

ថាយ ៖ សម្តីអាក្រក់ សម្តីអាក្រក់យ៉ាងម៉េច?

អ៊ីម ៖ ចា៎! សម្តីអាក្រក់តែចិត្តគាត់អត់អាក្រក់ទេ ។

ថាយ ៖ អត់អាក្រក់ទេនិយាយលេងសើចច្រើន?

អ៊ីម ៖ ចា៎! បើថាធ្លាប់ស្គាល់គ្នាជិតស្និតនិយាយគ្នាលេងសើចតាមធម្មតាដូចយើងស្គាល់គ្នាចឹងទៅណា ហីបើថាយើងខុសចឹងទៅគាត់កំហកដាក់ដូចស្អីចឹងទៅណា ហីបើទៅសុំអីគាត់ដូចថាហ៊ាតាអើយខ្ញុំសុំលុយ៤ទៅ៥រយចាយមកខ្ញុំអត់លុយចាយទេ ។

ថាយ ៖ ៤-៥០០បាតហ៎?

អ៊ីម ៖ ចា៎! គាត់ឲ្យហើយ នឹងអ្នកស្គាល់ជិតស្និតដែលធ្លាប់ចេញចូលទៅណា ។

ថាយ ៖ បាទ!

អ៊ីម ៖ ហើយខ្ញុំដល់ពេលមកជំបូងគាត់ឲ្យ៥០០បាត ។

ថាយ ៖ កាលទឹមនឹង ទឹមមកដល់ភ្នាមនឹងហ៎?

អ៊ីម ៖ មកដល់ភ្នាមគាត់ឲ្យ៥០០បាត ។

ថាយ ៖ គាត់មានសួរណាំអីអត់?

អ៊ីម ៖ គ្មានសួរអីទេ ប្អូនខ្ញុំគេឆ្លើយថាខ្ញុំយកបងខ្ញុំមកពីស្រុក ចឹងសុំឲ្យតាទទួលស្គាល់ផង ព្រោះអីនៅនោះអត់មានដីធ្វើស្រែទេ ។អញ្ចឹងហែងមិនយកមក ។

ថាយ ៖ គាត់ថាចឹង?

អ៊ុម ៖ នឹងហើយ! យកមក ថាអត់សោហ៊ុយហ្នឹងណា អត់សោហ៊ុយទៅអញឲ្យ ។ ឲ្យ១០០០ បាត ឲ្យប្អូនខ្ញុំឲ្យទៅខ្ញុំនឹងណា ឲ្យ១០០០បាតដល់មកខ្ញុំ មកដល់កន្លែង អនុងវែងនឹង គាត់ឲ្យ ៥០០ បាតទៀតគាត់ឲ្យទិញឆ្នាំង ទិញចានអីចឹងទៅណា ។

ថាយ ៖ ចឹងគាត់ឲ្យ១៥០០?

អ៊ុម ៖ នឹងហើយទាំងអស់គិតទៅវា១៥០០ ពិនអា១០០០នឹងគាត់ឲ្យប្អូនខ្ញុំទេ ខ្ញុំអត់បានឃើញ លុយទេ ។

ថាយ ៖ ហើយគាត់អ្នករៀបចំដឹកមីងមក?

អ៊ុម ៖ ចា៎! ប្អូនខ្ញុំដូចជាមានមេខ្យល់ទៅយកចឹងទៅណា គេជួលមេខ្យល់គេ ។

ថាយ ៖ បាទ!

អ៊ុម ៖ ពិននឹងខ្ញុំអត់បានឃើញលុយទេ ប្អូនខ្ញុំជាអ្នកឲ្យទេ ។

ថាយ ៖ បាទ!

អ៊ុម ៖ ហើយបើថាខ្ញុំមកដលនឹងគាត់ឲ្យ ។

ថាយ ៖ បាទ!

អ៊ុម ៖ យកមកសម្រាប់ទិញ ។

ថាយ ៖ មកដល់គាត់ឲ្យ៥០០ទិញអីខ្លះ?

អ៊ុម ៖ ទិញ! ឲ្យទិញឆ្នាំងទិញចានយកមកដាំបាយដាំអីហូបនឹងណា ។

ថាយ ៖ កាលនឹងកូនៗមីងមានអាយុប៉ុន្មានហើយ?

អ៊ុម ៖ កូនៗខ្ញុំអាបងគេបង្អស់អាយុ១៨ឆ្នាំ ។

ថាយ ៖ ប្រុស?

អ៊ុម ៖ ចា៎!ប្រុស ។

ថាយ ៖ ចុះបន្ទាប់ៗមក?

អ៊ុម ៖ បន្ទាប់មកអាយុ១៧ ។

ថាយ ៖ ១៧

អ៊ុម ៖ ១៣.១២ មានអា៩ឆ្នាំ ។

ថាយ ៖ អាបងគេអាយុ១៨?

អ៊ុម ៖ ចា៎!បងបង្អស់១៨ឆ្នាំ បន្ទាប់នឹងមក១៧ នែ៎មើលអាបងបង្អស់១៩ បន្ទាប់នឹងមក១៧ បន្ទាប់ នឹងមក១៥បន្ទាប់នឹងមក១៣.បន្ទាប់នឹងមក១០ឆ្នាំ បន្ទាប់នឹងមកប៉ុន្មានទេកាលនឹង ដូចជា ៧ឆ្នាំ ។

ថាយ ៖ ចឹងកូន៩?

អ៊ុម ៖ ចា៎!

ថាយ ៖ កូន៩?

អ៊ុម ៖ កូនខ្ញុំ៧នាក់ ។

ថាយ ៖ យកមកណោះ៧នាក់?

អ៊ុម ៖ ទាំងអស់កូនខ្ញុំ៧នាក់មកទាំងអស់ ។

ថាយ ៖ មកទាំង?

អ៊ុម ៖ ចា៎! តូចជាងគេអាយុ៩ឆ្នាំនឹងពៅគេ ។

ថាយ ៖ ចុះអ្នកដែលទៅនិយាយជាមួយតាម៉ុកសុំឲ្យគាត់ទទួលស្គាល់នឹងប្អូនមីង?

អ៊ុម ៖ ប្អូនខ្ញុំគេអ្នកនិយាយ ។

ថាយ ៖ ប្អូនប្រុស ឬប្អូនស្រី?

អ៊ុម ៖ ប្អូនទាំងប្ដីទាំងប្រពន្ធវា ។

ថាយ ៖ តែប្អូនបង្កើតមីងប្អូនប្រុសហ៎?

អ៊ុម ៖ ប្អូនខ្ញុំបង្កើតប្អូនប្រុស ប្អូនថ្លៃហើយនឹងប្អូនបង្កើតនឹងទៅនិយាយជាមួយតាម៉ុក ។

ថាយ ៖ ឥឡូវគាត់រស់ឯណា?

អ៊ុម ៖ នោះនៅ៨០០ហ៎ ។

ថាយ ៖ នៅ៨០០?

អ៊ុម ៖ ចា៎!

ថាយ ៖ នៅឯណា?

អ៊ុម ៖ នៅភូមិទំនប់លើ ។

ថាយ ៖ គាត់ធ្វើការឲ្យតាម៉ុកដែរ?

អ៊ុម ៖ កាលហ្នឹងប្អូនគាត់នៅបើកឡានឲ្យតាម៉ុកនឹង ។

ថាយ ៖ អូ៎! បើកឡានឲ្យហ៎?

អ៊ុម ៖ ចា៎!

ថាយ ៖ អូ៎! ចឹងបានហៅមកបាន ឯអ្នកធម្មតាប្រហែលជាមិនអាចហៅមកបានទេ ។

អ៊ុម ៖ មិនដឹងម៉េចទេ ។

ថាយ ៖ ចឹងពេលទៅយកនឹងគាត់ម្នាក់ឯងជាអ្នកយកឡានទៅយកមីង?

អ៊ុម ៖ អត់ទេ!

ថាយ : គាត់ប្រាប់ឲ្យគេយក?

អ៊ឹម : ឲ្យប្រាប់ឲ្យគេទៅយកតែឲ្យសោហ៊ុយ គឺនៅលើយើងទាំងអស់ ជិះឡានជិះអីលើយើង ប៉ុនតែឈ្នួលគេអ្នកទៅយកនឹងណា ។

ថាយ : ចុះពេលគេទៅប្រាប់មីងពីត្រាំកក់មក គាត់ទៅប្រាប់ថាម៉េច?

អ៊ឹម : ប្រាប់ម៉ែខ្ញុំឲ្យមកយកទៅអន្លង់វែង ។

ថាយ : គាត់ទៅខ្លួនឯងទៅយកខ្លួនឯង?

អ៊ឹម : ចាំ! ពូនឹងគាត់ទៅយកខ្លួនឯងទៅយកខ្ញុំនឹងណា ។

ថាយ : ពូដែលប្អូនមីងប្រាប់នឹង?

អ៊ឹម : អត់ទេ! ពូមេខ្យល់នឹងណា ពូមេខ្យល់ដែលប្អូនខ្ញុំជួលគេទៅនឹងណា ។

ថាយ : អូ៎! ជួលគេទៅៗឆ្លងព្រែកឆ្លងខ្សែត្រៀមឆ្លងអីទៅខាងហ៊ុនសែនទៅដល់តាកែវរត់ទៅប្រាប់?

អ៊ឹម : ចុះមេខ្យល់នឹងនៅតាកែវដែរនឹង ។

ថាយ : ប្រាប់ថាម៉េច?

អ៊ឹម : ប្រាប់ម៉ែខ្ញុំនឹងបងប្អូនខ្ញុំនឹងឲ្យមកយកឲ្យមកនៅអន្លង់វែង ព្រោះនេះវាសំបូរដីធ្វើស្រែ ហីតាមដីគេចែកឲ្យទៅកូនខ្ញុំច្រើនផង៧នាក់ឯណោះ គេចែកឲ្យតែ៤០អានឹងចិញ្ចឹមខ្លួន ម៉េចរស់ចិញ្ចឹមកូនម៉េចរស់ ។

ថាយ : នៅតាកែវនឹងហ៎?

អ៊ឹម : ចាំ! គេចែកឲ្យបានដែរ៤០អា ដល់ហើយក៏ខ្ញុំមកតាមគាត់មក ។

ថាយ : ទុកដីនឹងចោលឲ្យណាដីនឹង?

អ៊ឹម : ទុកដីនឹងឲ្យបងថ្លៃខ្ញុំធ្វើ ។

ថាយ : ពេលមកជុំរុំគេឲ្យ៤០អាដែរ?

អ៊ឹម : ចាំ! គេចែកឲ្យ៤០អាដែរ ពិនវាតិចពេលកូនច្រើនហ៎ណាដល់ពេលកូនការហើយបានអីចែកកូន ដល់ហើយក៏មកនេះមក ។

ថាយ : សម្រេចចិត្តអត់ខ្លាចទេ?

អ៊ឹម : នឹកឃើញគេថាអត់អីទេ សន្តិភាពហើយ ។

ថាយ : តែមិនទាន់បោះឆ្នោតហើយផងនឹង?

អ៊ឹម : នៅដល់ពេលដែលសន្តិភាពដាច់ខ្លួន គេចុះមកវិញបានបោះឆ្នោត ។

ថាយ : ចុះពីណាមកវិញ?

អ៊ីម : គេចខ្លួនទៅនៅឯស្រែណូយ ដល់ពេលឈប់រុករៀនគ្នាទៅ ឈប់វាយគ្នាទៅ បានគេហៅមកវិញ មកដល់បានបោះឆ្នោត ។

ថាយ : បោះឆ្នោត៩៨នឹងហ៎?

អ៊ីម : ចា៎!

ថាយ : ចុះ៩៣បោះនៅណា ទី១កាលអ៊ុនគាត់នៅ?

អ៊ីម : ទី១បោះនៅនេះតើ ។

ថាយ : នៅណា?

អ៊ីម : កាលអ៊ុន គាត់ នឹងអត់បានបោះទេ ។

ថាយ : អ៊ូ! ព្រោះនៅណោះហើយ?

អ៊ីម : ចា៎! មកនៅណោះនៅហើយ ។

ថាយ : ចឹងបានខ្ញុំចង់ដឹងថានៅណោះមានបោះនៅឯណា បោះនៅអន្លង់វែង គេអត់បោះទេកាលអ៊ុនគាត់?

អ៊ីម : បោះកាល អ៊ុនគាត់ អត់មានបោះទេ ។

ថាយ : បោះកាល៩៨ហើយនឹង?

អ៊ីម : ចា៎! កាលដាច់ខ្លួនមកវិញបាន បានបោះ ។

ថាយ : មេខ្យល់នៅតាកែវគេហៅមកច្រើន មីងធ្លាប់ដឹងថាគេមកនៅនេះច្រើនមកនៅ អន្លង់វែងមុនមីងមក ។

អ៊ីម : ទេបងប្អូនគេមកនៅនេះដ៏ហើយគេមកលេងបងប្អូនគេ ។

ថាយ : អ្នកតាកែវមួយចំនួនហ៎?

អ៊ីម : ចា៎! ឥឡូវបែកខ្ញែកគ្នាមិនដឹងទៅនៅភូមិណាភូមិណីអស់ហើយកាលនឹងនៅជិតៗគ្នា ឥឡូវវាបែកខ្ញែកគ្នា ។

ថាយ : អ៊ូ! ពេលមកដល់ដំបូង?

អ៊ីម : ពេលមកដល់ដំបូងនៅជិតៗគ្នា ។

ថាយ : អ្នកមកពីតាកែវនឹងហ៎?

អ៊ីម : ចា៎! តែឥឡូវបែកខ្ញែកគ្នាខ្លះគេទៅនៅស្រុកវិញ ទៅស្រុកវិញអស់ខ្លះ ចឹងគេទៅនៅភូមិណា ឃុំណាអស់ទៅណា ។ មកនេះអត់មានអ្នកតាកែវទៅ អត់សូវមានអ្នកតាកែវទេមួយៗ ។

ថាយ : អន្លង់វែងនឹង?

អ៊ីម : នែ៎! ភូមិនេះ ។

ថាយ : ភូមិនេះហ៎! ចុះនៅម្តុំផ្ទះតាម៉ុក សំបូរដែរទេ?

អ៊ីម : កាលនឹងសំបូរដែរតើ តែឥឡូវមិនដឹងគេទៅឯណាឯណីខ្ញុំមិនដឹងដែរ ។ កាលពីខ្ញុំនៅនឹងច្រើនតែពីតាកែវ ហើយនឹងកំពត កំពង់ឆ្នាំងអត់សូវមានទេ ។

ថាយ : បាទ! ចឹងមីងមកដល់មីងនាំកូន៧នាក់នាំទាំងប្តីមីងផង មកដល់ធ្វើស្រែចម្ការ?

អ៊ីម : ចា៎! មកដល់ធ្វើស្រែចម្ការ ។

ថាយ : ហើយមានអីទៀតមីងជួយរៀបរាប់សាច់រឿង នឹងបទពិសោធន៍នៅអន្លង់វែង?

អ៊ីម : មិនដឹងមានរឿងអីទៀត ។

ថាយ : ចឹងពេលនៅទៅបានស្រូវបានអីទៅ ពេលគេវាយចូកមកក៏រត់ទៅ រត់ចោល?

អ៊ីម: រត់ចោលពីនឹងក៏មានគេដុតអស់ទៅដល់ពេលកាលខ្លាចខ្លួនទៅនៅស្រែណូយ នឹងស្រូវមកដល់ខ្លះក៏គេយកអស់ទៅខ្លះទៅផ្ទះ គេរុសអស់ទៅដល់ខ្ញុំភ្លើងឆេះផ្ទះអស់លីង គេដុតចោលអស់ផ្ទះ ។

ថាយ : មុនពេលចេញគេដុត?

អ៊ីម : ចា៎!

ថាយ : ពេលចេញទៅគេដុត?

អ៊ីម : រៀបចេញទៅគេដុតចោល ។

ថាយ : ហេតុអី?

អ៊ីម : មិនដឹងទេ មកវិញអត់មានផ្ទះនៅទេ ខ្ញុំក៏ដើរនៅជាមួយគេ គេអ្នកផ្ទះនឹងគេនៅ សល់ចឹងទៅនៅជាមួយគេទៅ ។

ថាយ : ផ្ទះមីងប៉ុន្មានដែលគេដុតនឹង?

អ៊ីម : នែ៎! កាលគេដុតចោលនឹងទទឹង៦ បណ្តោយ៧ តែនៅសល់បានស្រូវគេកើបយកខ្លះ គេទុកឲ្យខ្លះ ហីបើថាមាន់ទាអីគេចាប់យកអស់រលីង ។

ថាយ : ចុះនៅពេលរត់ទៅគេចូលដល់ទេ ទាហានខាងហ៊ុនសែនចូលដល់ទេ?

អ៊ីម : ចូលដល់តើ ។

ថាយ : ចូលដល់! ទាហានខាងហ៊ុនសែន?

អ៊ីម : ចា៎!

ថាយ : ដល់ពេលមកវិញមីងធ្វើអីខ្លះទៀត ពេលមកវិញ?

អ៊ីម : មកវិញអត់ហានដើរក្នុងព្រៃទេខ្លាចមីន ព្រោះអីមីនមាននៅពេញក្នុងព្រៃ ។

ថាយ ៖ ហេតុអីអ្នកណាកប់មីននឹង?

អ៊ុម ៖ មិនដឹងអ្នកណា ខ្ញុំអត់ដឹងដែរ ដល់មកវិញឃើញផ្ទុះផាប់ៗគោរអីពាសទឹកពាសដី មិនដឹងឯណាមិនដឹងឯណី មិនដឹងជាមីនខាងណា មិនដឹងជាទាហានខាងណាដាក់ តែបើទាហានខ្មែរក្រហមមិនបានដាក់ទេដឹង បើគ្រាន់ហ៎ាមកដល់ហើយផឹបៗអីក៏ម៉េចទេមិនដឹង ទាហានមួយណាទេអ្នកដាក់នឹងបើរត់ទៅឈូរទៅទាំងអស់គ្នាទៅ ដល់ពេលនេះបានបកមកពីលើវិញប្រុសៗគេមកកាន់កាំភ្លើងមកវិញ មិនដឹងទាហានខាងណាដាក់ម៉ីននឹង ខ្ញុំមិនសូវដឹងដែរ ។

ថាយ ៖ ចុះមីងពេលមកប្តីមីងហើយនឹងកូនប្រុសច្បងគេឲ្យបំរើការអីដែរ?

អ៊ុម ៖ អត់ទេ អត់បានចូលបំរើការផង ។

ថាយ ៖ ចុះគេអត់ហៅចូលបំរើការអីទេ?

អ៊ុម ៖ ចុះកូនខ្ញុំវាទៅរៀន ។

ថាយ ៖ មានសាលារៀនដែរ?

អ៊ុម ៖ កាលនៅជំរុំនឹងរៀនដល់ពេលមកដល់នេះ វាអត់ទាន់បានចុះឈ្មោះរៀន ។ ដល់វាឈប់រៀនចាប់ពីពេលនោះមកចឹងទៅដល់ហើយវាក៏ធ្វើគ្រូរហូត ។

ថាយ ៖ ធ្វើគ្រូ?

អ៊ុម ៖ ចា៎!

ថាយ ៖ ធ្វើគ្រូនៅណា នៅកន្លែងណា ធ្វើគ្រូឲ្យតាម៉ុកនឹង?

អ៊ុម ៖ អត់ទេ! បើមីស្រីនោះ អាប្រុសនោះមកធ្វើពេលមកពីគេចខ្លួនវិញ បើមីស្រីនោះធ្វើតាំងពីសម័យតាម៉ុក ស្រីទី៣ ។

ថាយ ៖ ធ្វើពីសម័យ តាម៉ុក បង្រៀនអីគេ?

អ៊ុម ៖ បង្រៀនកូនសិស្សនឹងបង្រៀនកូនក្មេងនឹងណា ។

ថាយ ៖ អ៎ូ! នៅសាលាតាម៉ុកសង់នឹង?

អ៊ុម ៖ ចា៎!

ថាយ ៖ អាគារបីជាន់នឹង?

អ៊ុម ៖ មិនមែនទេ សាលាយើងតាមភូមិ ។

ថាយ ៖ ចុះប្តីហើយនឹងកូនប្រុសអត់បានចូលទេ តែភាគច្រើនចាប់ប្តីហើយនឹងកូនប្រុសឲ្យចូលបំរើទាហាន?

អ៊ុម ៖ នឹងគេនៅយូរហើយ ។

ថាយ ៖ យើងមកថ្មីចឹងអត់ទេ?

អ៊ុម ៖ ទើបមកថ្មីចឹងគេអត់មានហៅឲ្យចូលទេ ។

ថាយ ៖ ចឹងពេលមីងមកនៅអន្លង់វែងនឹងគេអត់មានទារពន្ធ ទារអីពីមីងទេ?

អ៊ុម ៖ ចា៎! អត់មានទារពន្ធ ទារដារអីទេ យើងធ្វើប៉ុណាហូបប៉ុណ្ណឹងទៅ

ថាយ ៖ ហើយមីងរត់ឡើងភ្នំប៉ុន្មានដងកាលពីជំនាន់នឹង?

អ៊ុម ៖ ទើបតែឡើងបាន១ដង ។

ថាយ ៖ ទើបតែឡើងម្តងទេ ក្រោយពីម្តងនឹងមក គឺឈប់រហូត ។

អ៊ុម ៖ ចា៎! ក្រោយពីម្តងនឹងមកឈប់រហូត ចុះបើប្រជាជនបះបោរចូលទៅក្នុងអស់ហើយនឹងរត់តាំងពីនឹងមក ។

ថាយ ៖ មីននៅជិតផ្ទះតាម៉ុកនឹងមីងបានរៀបរាប់បានខ្លះៗ ហើយថាជួនកាលគាត់សម្តីតាម៉ុកអាក្រក់ស្តីឲ្យខ្លាំងៗ នឹងពេលល្អក៏ល្អដែរ?

អ៊ុម ៖ ចា៎!

ថាយ ៖ ចុះគាត់នឹងជាមនុស្សយ៉ាងម៉េចទៀត?

អ៊ុម ៖ ការដឹងដូចថាជួនកាលគាត់ដូចជាមនុស្សប្រសែប្រសាទបន្តិចត្រូវល្អៗទៅ ត្រូវលំ៉ អាក្រក់គឺអាក្រក់មួយភ្លាតគាត់ដូចជាចិត្តឆេវឆាវចឹងណាដូចគាត់សរសៃប្រាសាទគាត់ចុះគាត់កំបុតជើង ។

ថាយ ៖ កំបុតតាំងពីអន្លាល់ណាមក?

អ៊ុម ៖ មិនដឹងកំបុតតាំងពីជំនាន់ណាទេ?

ថាយ ៖ មីងមកដល់គាត់កំបុតជើង ហេតុអីបានជាគាត់កំបុតជើងដឹងទេ?

អ៊ុម ៖ មិនដឹងជាម៉េចទេ ខ្ញុំអត់សួរដឹងដែរ ។

ថាយ ៖ តាម៉ុកគាត់មានប្រពន្ធមានកូនរបស់ដែរ?

អ៊ុម ៖ មាន ។

ថាយ ៖ គាត់មានប្រពន្ធប៉ុន្មានដែរដឹងទេ?

អ៊ុម ៖ ឮគេនិយាយគេថាប្រពន្ធ២ ។

ថាយ ៖ គាត់នៅផ្ទះជាមួយគ្នា ។

អ៊ុម ៖ ប្រពន្ធមុនស្លាប់ហើយបានគាត់យកមួយទៀត ។

ថាយ ៖ ចុះនៅផ្ទះគាត់នឹងប្រពន្ធគាត់នៅជាមួយគ្នា?

អ៊ុម ៖ អត់ទេ ឥឡូវមិនដឹងថាគេចទៅឯណាឯណីអស់ហើយទេ ។

ថាយ ៖ អត់ទេកាលពីមីងមកនៅជំបូងជិតផ្ទះតាម៉ុកនឹងប្រពន្ធរបស់គាត់នឹងនៅមួយគ្នាដែរអត់?

អ៊ុម : នៅតើប្រពន្ធចុងក្រោយ ។

ថាយ : ហើយម៉េចទៀតបន្ទាប់ពីតាម៉ុកគាត់បានស្លាប់បាត់ហើយ គាត់ជាមេដឹងនាំនៅក្នុងតំបន់នេះយូរហើយចឹង យើងចង់ដឹងពីប្រវត្តផ្ទាល់ខ្លួន របស់គាត់ខ្លះតាមរយៈអ្នកនៅជិតចឹង?

អ៊ុម : ខ្ញុំមិនសូវដឹងដែរក្រោយពីនៅជាមួយគាត់បានប៉ុន្មានឆ្នាំក៏របាត់របាយគ្នាអស់ទៀតទៅ ខ្ញុំមិន សូវដឹងពីចរិកគាត់ប៉ុន្មានដែរព្រោះអីខ្ញុំមិនបានទៅជិតដល់ជាមួយគាត់ប៉ុន្មានទេ គ្រាន់តែបានមួយឃើញគាត់ ទៅទំនាក់ទំនងជាមួយគាត់ចឹងខ្ញុំមិនដែលទៅទំនាក់ទំនងជាមួយគាត់ទេណា ឃើញតែគាត់ជិះឡានតាមថ្នល់ ឃើញគាត់ឈរបញ្ជារគេធ្វើស្ពានធ្វើអីចឹងទៅណា ហឺបើថា ឃើញឡានមកចឹងគាត់កាក់ឡាននឹងឲ្យឈប់រើសថ្មដាក់រួចបញ្ជារចេះទៀតថាពួកហ៊ើងង៉ែងចុះមកប្រមូលថ្មដាក់ក្រាលស្ពានបានឲ្យទៅ បើមិនចឹងអត់ឲ្យទៅទេបាននាំគ្នា ចុះជួយទាញទៅដាក់ពេញទៅ គាត់ថាទៅៗ ។

ថាយ : អ៎ូ! ឡានចុះពីភ្នំមក?

អ៊ុម : ចា៎! ចុះរើសដាក់ពេញទៅគាត់ឲ្យទៅ ហឺសម្ដីគាត់អត់មានហៅអាអូន មីនាងអីទេ សុទ្ធហ៊ើងង៉ែង ។

ថាយ : ង៉ែង ហ៊ើងទាំងអស់នឹង?

អ៊ុម : ចា៎! នឹងតាមខ្ញុំឮនឹងត្រចៀកខ្ញុំទេណា ។

ថាយ : បាទ! ឮត្រចៀកឯង ខ្លួនឯង?

អ៊ុម : ចា៎! អត់មានឮមាត់គេមកនិយាយ ពួកង៉ែង ហ៊ើង ចុះមក ។ ហឺ បើប្អូនខ្ញុំក៏ចឹង ដែរដើរកាត់មុខផ្ទះគាត់ គាត់សួរទៅណាហង ង៉ែងមកធ្វើអីហងនឹងខ្ញុំឮតាមប្អូនខ្ញុំនិយាយទេ ខ្ញុំផ្ទះជិត គាត់ខ្ញុំមិនដែលចូលទេ បើដើរកៀន ដើរទៅស្រែទៅចម្ការដើរទៅតាមកៀនផ្ទះគាត់ ។

ថាយៈ មីងខ្លាចគាត់?

អ៊ុម : មីងខ្លាចដែរនឹង គេអ្នកធំ ។

ថាយ : ចុះបឹងនៅជិតផ្ទះគាត់នឹងគេធ្វើយូរនៅ?

អ៊ុម : ធ្វើតាំងពីគាត់ធ្វើស្ពានបឹងហ្នឹង នៅរហូតកាលនឹងពោះអូរទេ ។

ថាយ : ពេលទឹកវាអត់ហូរវាកាន់តែរីកទៅៗ ។

អ៊ុម : (ស្ដាប់មិនបាន) កាលពីអត់ទាន់លើកហ្នឹងសុទ្ធតែដើមឈើដើមបន្ទាល អោបមួយជុំៗឡើងជ្រោង ។ ឥឡូវដល់ពេលគេធ្វើស្ពានលើកទំនប់ចឹងមក (ស្ដាប់មិន បាន) ។

ថាយ : ចុះមិនមានដែលបានឃើញតាម៉ុកចាប់អីអ្នកណាអ្នកណីនៅផ្ទះគាត់រាល់ថ្ងៃហ្នឹង មានទ្រង់មួយ?

អ៊ឹម : ដូចមិនដែលឃើញ ។

ថាយ : មិនដែលឃើញទេ?

អ៊ឹម : ខ្ញុំមិនដែលបានឃើញបានដឹងផង បើអ្នកទោសធ្ងន់នឹងដូចថាលួចគេ ឬមួយក៏វាយគេ ។

ថាយ : អូ៎! សម័យតាម៉ុកមានគេលួចប្លន់គេដែរ?

អ៊ឹម : ទេ! ខ្វះចឹងដែរមួយៗចឹងដែរ ពិនលួចនឹងមានមួយៗចឹងទៅណា ចុះមានអ្នកណាទៅ ហ៊ាន គោះចាប់បានដឹងតិ៍មិនត្រឹមតែចូលទ្រង់ទេបាញ់ចោលទៀតណោះ ។

ថាយ : ចឹងលួយចគេ?

អ៊ឹម : ប្លន់ហើយនឹងលួចគេហ្នឹងមិនបានទេ(ស្តាប់មិនបាន) ។

ថាយ : ចុះបើចាប់បានគេយកទៅគក់ត្រង់ណា មានគក់របស់គេដែរ?

អ៊ឹម : (ស្តាប់មិនបាន)ដូចមិនដែលមានចោរលួចចោរប្លន់អីជំនាន់កាលហ្នឹង

ថាយ : កម្រ?

អ៊ឹម : ចា៎! កម្រមានណាស់ ។

ថាយ : ចុះបើធ្វើបុណ្យធ្វើទានអីយើងទៅវត្តនៅឯណា អត់ធ្វើវត្តឯណា?

អ៊ឹម : ដូចជាអត់មានទេ ដូចជាមានវត្តអន្លង់វែងមួយដែរតើ ។

ថាយ : ជំនាន់ណា ជំនាន់តាម៉ុកដែរ?

អ៊ឹម : មិនដឹងជាគេធ្វើជំនាន់ណាទេ ។

ថាយ : ទល់ពេលភ្ជុំគេឲ្យយើងទៅវត្តដែរ?

អ៊ឹម : អត់មានទៅផង ។

ថាយ : គេអត់ឲ្យទៅទេ?

អ៊ឹម : មិនដែលស្គាល់វត្តអន្លង់វែងនៅកន្លែងណាផង ។

ថាយ : ចឹងតាំងពីមកមីងមិនដែលបានទៅវត្តនឹងទេ?

អ៊ឹម : មកនៅអន្លង់វែងហ្នឹងប៉ុន្មានឆ្នាំអត់ដែលបានទៅវត្តហ្នឹងផង ។ បើចូលឆ្នាំអីយើងលេងៗ តែគ្នាយើងចឹងទៅ ។

ថាយ : លេងអីខ្លះ?

អ៊ឹម : លេងរបាំប្រជាប្រិយ ដូចតែយើងមានវត្តដែរនឹងណា ។ បើពេលភ្ជុំយើង នាំគ្នារៀចអន្សម រៀចអី នាំកូននាំចៅស៊ីចឹងទៅ អត់ទៅវត្តអត់មានលោក ។

ថាយ : ម៉េចចឹង?

អ៊ុម : មិនដឹង?

ថាយ : គេអត់ឲ្យមាន?

អ៊ុម : មិនដឹងម៉េចអត់ឃើញមាន ។

ថាយ : កាលម័យខ្មែរក្រហមគេអត់ឲ្យមាន?

អ៊ុម : កាលខ្ញុំមកនៅនឹងអត់មានវត្តទេ នៅស្រុកបានមានវត្តបានៗទេ ។

ថាយ : ចុះឥឡូវភូមិនេះចង់ទៅវត្តនឹងវត្តនៅឯណា?

អ៊ុម : នៅនេះ ។

ថាយ : នៅឯណា?

អ៊ុម : នៅជិតនេះ ។

ថាយ : នៅជិតនេះទេ ទឹមធ្វើ?

អ៊ុម : ចា៎! ធ្វើជិត១០ហើយទេដឹង ។

ថាយ : ហើយមានវត្តណាទៀតទេភូមិមីង?

អ៊ុម : ជិតនេះមានតែវត្តហ្នឹងវត្តពពារ ហើយនឹងវត្តនរាជិតទៅមក ពិនតែជិតជាងគេគឺវត្តហ្នឹង ។

ថាយ : មីងមានដែលឃើញគេចាប់អ្នកតាអី ចូលរូបចូលអី មានដែលឃើញ(ស្តាប់មិនបាន) ។

អ៊ុម : ដូចមិនដែលឃើញទេ ឮតែគេថា ។?

ថាយ : ឮម៉េច?

អ៊ុម : កុមារីម្នាក់មានចាស់មាន ក្មេង មិនដឹងជាគេចាប់ឮអីទេដឹហើយមីងមកដល់ស្រាប់តែឮគេចាប់យកទៅ មិនដឹងជាគេ ចាប់យកទៅមិនដឹងជាចាប់យកទៅឯណា ឮតែថាចាប់បាត់ៗ ។

ថាយ : យកតែកុមារីហ្នឹងទេ?

អ៊ុម : ចា៎! យកទាំងម៉ែទាំងឪអីក៏អីទេ ឮសួរគេចាប់បាត់ៗ ។

ថាយ : ម៉េចបានជាគេចាប់?

អ៊ុម : មិនដឹង ។

ថាយ : អាចថាមានអីចូលសន្និតចូលរូបចូលអី?

អ៊ុម : ចា៎! ខ្លះគេមានអបិយជំនឿរចឹងៗ ។

ថាយ: មានអបិយជំនឿ អើចេះមីងខ្ញុំសុំសួរខាងដើមវិញនៅពេល មីងទៅដល់ជំរុំហើយ នឹងនៅខ្ទង់បែកប្រហែល ជាប៉ុន្មានឆ្នាំបានមកដល់ជំរុំឆ្នាំ៨០ជាង?

អុឹម ៖ អើដូចជា៧៦អីមិនដឹងទេ បើ៧៨នៅ ។

ថាយ ៖ ៧៩រត់មក?

អុឹម ៖ ៧៩រត់មកនូវនេះ អូរអន្ទក់អូរត្រាវអីនឹង ហើយមកដល់អូរត្រាវអីហ្នឹងនៅបានប៉ុន្មានខែ បានចូលនៅថៃ ។

ថាយ ៖ ឆ្នាំ៧៩ហ្នឹងហើយចុងឆ្នាំអីក៏ពាក់កណ្តាលឆ្នាំ(ស្តាប់មិនបាន)?រហូតដល់ជំនាន់ អ៊ុនតាក់ ពេលចូលមក ។

អុឹម ៖ ចាំ! ពេលចូលមកបានកាក់កាបាទក្រហមគេថាស្រុកទេសយើងមានសន្តិភាពអស់ហើយ ។

ថាយ ៖ គេបំបែក?

អុឹម ៖ ហ្នឹងហើយបានគេឲ្យស្រុកណា គេឲ្យមកហ្នឹងទៅណា ។

ថាយ ៖ បាទ!

អុឹម ៖ គេដឹកមកដាក់ដល់កន្លែង ។

ថាយ ៖ អូ៎! យើងប្រាប់ទៅគេដឹងមកដល់ហ្នុង?

អុឹម ៖ ចាំ! ដឹកដាក់ដល់ ដល់ភូមិយើងនៅ ។

ថាយ ៖ បាទ! ចុះគេដឹកដាក់ដល់ទៅគេមានចែកដីចែកអីឲ្យ?

អុឹម ៖ អត់ទេប្រធានភូមិ ប្រធានឃុំគេអ្នកចែកឲ្យ ។

ថាយ ៖ ចែកឲ្យហ៎?

អុឹម ៖ ចាំ! គេបានចែកលុយឲ្យយើង ។

ថាយ ៖ មីងជួបអ្នកខ្មែរក្រហម អ្នកធ្លាប់ធ្វើការខាងអ្នកនិរតីអ្នកធ្លាប់ធ្វើការបដិវត្តន៍ធ្វើអី?

អុឹម ៖ អ្នកធ្លាប់ធ្វើការកាលពីខ្ញុំនៅហ្នឹង រត់គេចខ្លួនខ្លះមកនៅបាត់ដំបង ពោធិ៍សាត់អត់ហានចូលស្រុកវិញណា ។

ថាយ ៖ ចុះអត់ពេញចិត្តអ្នកមកពីនោះទេ?

អុឹម ៖ ស្អប់! ដូចថាប្រធានភូមិ ប្រធានឃុំ អត់មានអ្នកណាហ៊ានចូលស្រុកវិញទេ ប្រធានភូមិ ប្រធានឃុំយើងកាលពីជាសម័យណោ៎ះ អត់មានអ្នកណាហានូលមកនៅ អត់មានអ្នកណាហាន ចូលនៅស្រុកភូមិវិញទេ ។ គ្រាន់តែលបចូលទៅ គេស៊ើបដឹងថាមកទៅដឹងថាមក អត់ហាន ដេកនៅផ្ទះទេ ដេកក្នុងព្រៃ ទៅបានតែមួយយប់ទេដេកនៅព្រៃ រត់មកវិញទៅ គេរក សម្លាប់ចោល ។

ថាយ ៖ មីងដឹងតើអ្នកណានិយាយប្រាប់មីង?

អុឹម ៖ បងថ្លៃខ្ញុំនិយាយប្រាប់ខ្ញុំ ។

ថាយ ៖ ពេលមីងមកដល់អន្លង់វែងនេះហើយហ្នឹង?

អ៊ុម ៖ កាលខ្ញុំទៅដល់ស្រុកហើយហ្នឹង បងថ្លៃខ្ញុំគាត់និយាយប្រាប់ ។

ថាយ ៖ អ្នកនិយាយប្រាប់?

អ៊ុម ៖ រួចសួរថាពួក ម៉ៅ ពួកអីគេទៅនៅណាអស់ឥឡូវ ថាហ៊ីនាងងាប់បាត់តាំងពីម៉្ងឹកហ្នឹង អាផុន ឃើញគេលបមកម្តង គេរកដេញកាប់រត់ទៅដេកក្នុងព្រៃមកបានតែមួយយប់ ក៏វិលទៅបាត់ដំបងវិញបាត់ទៅទាំងក្រុមគ្រួសារគេនឹង ។

ថាយ ៖ ចុះមីងនៅត្រាំកក់ហ្នឹងបានតែប្រហែលមួយវស្សាបានមីងមកណោះ?

អ៊ុម ៖ ចា៎! ទៅដល់ស្ទូងហើយ ច្រូតហើយ បោកបែនហើយមកណោះទៅ ស្រូវអត់បានហូបផង ។

ថាយ ៖ ហើអើដល់ពេលមីងមកនៅតំបន់អន្លង់វែង ស្រុកអន្លងវែងនេះ ក្រោមការដឹកនាំរបស់តាម៉ុក ហើយមានសង្គ្រាមមានអីរត់ភ្លើលទៅភ្លើលមកមីងមានស្តាយទេ?

អ៊ុម ៖ និយាយទៀងមិនស្តាយម៉េច ។

ថាយ ៖ ស្តាយម៉េច?

អ៊ុម ៖ ស្តាយបេះស្តាយដូចថាយើងខំហើយហ្នឹងណា ខំបានហើយរត់ចោលទៅវាស្តាយកម្លាំងស្តាយរបស់ដែលយើងខំធ្វើបានហើយ ខំធ្វើកើតហើយហ្នឹង ។

ថាយ ៖ របស់នៅអន្លង់វែងហ្នឹងមានអី?

អ៊ុម ៖ ដូចថាស្រូវអង្ករហ្នឹងណា ខំធ្វើហត់នឿយ ដំហើយយើងរត់ចោលទៅ ហើយបាងត់តាំងពីគោ ជ្រូក មាន់ ទា ដំរត់ចោលអស់ទៅមកវិញអស់លីង ។

ថាយ ៖ កាលពីគេសម្លាប់ សុន សេន មីងមានព្រឹត្តិមានអី គេនិយាយយ៉ាងម៉េចដែរ?

អ៊ុម ៖ កាលគេសម្លាប់គេសម្លាប់នៅលើភ្នំណោះ មិនដឹងជាយ៉ាងម៉េចទេ ខ្ញុំក៏មិនដឹងដែរ ។ ឃើញតែរូបថតគេដាក់បិទនៅខាង ឃើញតែរូបថតទេ ។

ថាយ ៖ កាលណោះមីងនៅជិតផ្ទះតាម៉ុកដែរ?

អ៊ុម ៖ ខ្ញុំនៅនេះហើយហ្នឹង ។

ថាយ ៖ មកណោះហើយ?

អ៊ុម ៖ ចា៎!

ថាយ ៖ ចុះមីងយល់យ៉ាងម៉េចដែរ?

អ៊ុម ៖ ខ្ញុំយល់យ៉ាងម៉េចទេ ខ្ញុំមិនសូវដឹងដែរ ។ ប៉ុន្តែគ្រាន់តែសម្លាប់ដូចវាសាហាវ ។

ថាយ ៖ សាហាវ?

អ៊ឹម ៖ សាហាវ ចុះបើសម្លាប់គេមួយពូសម្លាប់ទាំងអស់ហើយសូម្បីតែកូនតូចមួយក៏មិនទុកដែរ ។

ថាយ ៖ ហេតុអី?

អ៊ឹម ៖ មិនដឹងៗជាវាទឹងស្អីបានជាសម្លាប់ចឹង ។

ថាយ ៖ ពូថាមានរំលោភដែរ?

អ៊ឹម ៖ រំលោភកូនក្រមុំៗហ្នឹងស្រាតគ្នាអស់រលីង ។

ថាយ ៖ ឃើញក្នុងរូបថត?

អ៊ឹម ៖ ចា៎! ឃើញក្នុងរូបថតគេបិទរូបឲ្យយើងមើលចឹងទៅណា តែមើលទៅដូចវាស្ដែង ឃាមហូរកាត់ថ្ពក ចុះបើមួយគ្រួសារអស់រលីង ។

ថាយ ៖ ហើចុះកាលនោះគេថាអ្នកណាជាអ្នកធ្វើ?

អ៊ឹម ៖ អត់ដឹងដែរ ។

ថាយ ៖ គេគ្រាន់បិទរូបឲ្យយើងមើលទេ?

អ៊ឹម ៖ គេគ្រាន់បិទឲ្យយើងមើល មិនដឹងមួយណាគេអ្នកធ្វើផង ។

ថាយ ៖ មីងមានសល់រូបអីទេ រូបពីជំនាន់ហ្នឹង?

អ៊ឹម ៖ អត់ទេ ។

ថាយ ៖ ហើយដល់ពេលកើតឡើងហើយ ចុះពេលគេទៅចាប់ប៉ុលពតមីងមានដឹងពត៌មាន គេកាត់ទោស ប៉ុល ពត មីងមានបានចូលរួមទេ?

អ៊ឹម ៖ ពូគេថាកាត់ទោសៗដឹងយ៉ាំងម៉េចទៅ គេឯលើភ្នំ?

ថាយ ៖ រួចបានគេហៅទៅ កាលមីងមកនៅណេះគេមានហៅទៅបង្រៀននយោបាយទេ រៀនសូត្រ អត់ដែរទៅចូលរួមអីទេ?

អ៊ឹម ៖ អត់ទេ! យើងមកថ្មីចឹងគេមិនដែលឲ្យយើងចូលកន្លែងគេទេ ។

ថាយ ៖ អត់ឲ្យចូលរៀននយោបាយទេ?

អ៊ឹម ៖ អត់ទេ!

ថាយ ៖ អ្នកភូមិមួយចំនួនអ្នកចាស់គេហៅទៅតើ?

អ៊ឹម ៖ អ្នកចាស់ៗគេហៅ ខ្ញុំទើបនឹងមកថ្មីគេដែលឲ្យចូល ។

ថាយ ៖ មីងស្គាល់អ្នកមកថ្មីជានរណាទេ?

អ៊ឹម ៖ អត់! ខ្ញុំដឹងតែខ្លួនខ្ញុំមួយជាអ្នកមកក្រោយគេ ក្រៅពីនោះគេមកមុនខ្ញុំ ។

ថាយ ៖ ហើយមីងរស់នៅតំបន់អន្លង់វែងភ័យខ្លាំងបានចេះតែរត់រហូតចឹង?

អ៊ឹម ៖ ភ័យ(ស្ដាប់មិនបាន)ភ័យខ្លាចកើតខ្យល់កើតអីចឹងទៅណា ។

ថាយ ៖ ខ្លាចអី?

អ៊ីម ៖ ចេះតែខ្លាចទៅ ខ្លាចតែគ្រាប់ (ស្តាប់មិនបាន) ។

ថាយ ៖ ចុះនៅត្រាំកក់ដូចអត់កើតចឹងទេ?

អ៊ីម ៖ អត់ទេ ។

ថាយ ៖ ត្រាំកក់ដូចអត់មាន?

អ៊ីម ៖ អត់មាន បើមានៗតែ(ស្តាប់មិនបាន) ។

ថាយ ៖ អត់ទេត្រាំកក់ពេលមកពីជំរុំហើយ?

អ៊ីម ៖ អត់ទេ ។

ថាយ ៖ អត់ទេ?

អ៊ីម ៖ ចា៎!

ថាយ ៖ ចុះមីងគេពីកន្លែងដែលអត់មានសង្គ្រាមមកកន្លែងមានសង្គ្រាម?

អ៊ីម ៖ ចុះបើបែកម៉ែយូរឆ្នាំពេក ។

ថាយ ៖ ម៉ែនៅណោះស្រាប់?

អ៊ីម ៖ នឹកម៉ែក៏ម៉ែឲ្យមកណោះមក ។

ថាយ ៖ គាត់នៅ?

អ៊ីម ៖ ម៉ែខ្ញុំនៅ ។

ថាយ ៖ អាយុប៉ុន្មានហើយ?

អ៊ីម ៖ ម៉ែខ្ញុំដូចជាប៉ែតជាងហើយ ជិតមួយរយហើយ ។

ថាយ ៖ ចុះឪពុក?

អ៊ីម ៖ ឪពុកខ្ញុំស្លាប់ហើយ ។

ថាយ ៖ ម៉ែមីងនៅគាត់នៅតាំងពីជំនាន់ លន់ នល់ អីនៅអន្លង់វែងរហូត?

អ៊ីម ៖ ចា៎! ម៉ែខ្ញុំគាត់ចាស់ហើយ ។

ថាយ ៖ ចុះប្អូនប្រុសមីងដែលបើកឡានឲ្យ តាម៉ុក នៅឯណាឥឡូវ?

អ៊ីម ៖ នៅហ្នឹងជិតម៉ែខ្ញុំនឹង ។

ថាយ ៖ ជិតម៉ែនៅណា ភូមិណា ឃុំណា?

អ៊ីម ៖ ភូមិទ្រនប់លើ ។

ថាយ ៖ ភូមិទ្រនប់លើ ឃុំ?

អ៊ីម ៖ ឃុំស្អីទេ រឿងឃុំអត់ស្គាល់ឃុំគេទៀតស្គាល់តែភូមិ ។

ថាយ ៖ នៅខាងណាទីរួមស្រុក?

អ៊ឹម ៖ ដូចជាឃុំត្រពាំងព្រៃអីទេ ។

អ្នកភូមិ៖ ឃុំត្រពាំព្រៃ ។

ថាយ ៖ ឃុំត្រពាំព្រៃ ហើយប្អូនប្រុសមីងឈ្មោះអី?

អ៊ឹម ៖ ប្អូនខ្ញុំនៅនោះ២-៣នាក់ ។

ថាយ ៖ ដែលបានស្លាប់ហើយ ធ្វើការឲ្យតាម៉ុកទាំងអស់?

អ៊ឹម ៖ ចាំ! ធ្វើការឲ្យតាម៉ុកទាំងអស់ ។

ថាយ ៖ ឈ្មោះអី?

អ៊ឹម ៖ ឈ្មោះ គាន់ បើកមែខូកាន់. ។

ថាយ ៖ ហើយមួយទៀត?

អ៊ឹម ៖ ទូច ក៏បើកឡាន ។

ថាយ ៖ បើកឡានដោយផ្ទាល់ហ្មង?

អ៊ឹម ៖ អត់ទេបើកឡានដឹកដីដឹកអី ធ្វើស្ពាន ធ្វើទំនប់អីហ្នឹង មិនមានបើកផ្ទាល់ទេ ។

ថាយ ៖ ចុះ តាម៉ុក គាត់ស្លាប់គេហែសព មីងមានបានទៅចូលរួមទេ?

អ៊ឹម ៖ អត់ ។

ថាយ ៖ អត់ទេ មីងមានអារម្មណ៍ម៉េចដែរពេលគាត់ស្លាប់?

អ៊ឹម ៖ មានអារម្មណ៍អីធម្មតា ។

ថាយ ៖ (ស្តាប់មិនបាន) នៅពេលចប់សង្គ្រាម មីងមានអារម្មណ៍ យ៉ាងម៉េច ដែរ?

អ៊ឹម ៖ មានអារម្មណ៍ថាលែងមានសង្គ្រាមសប្បាយចិត្ត ។

ថាយ ៖ សប្បាយចិត្តហើយនៅទីនេះរហូតទៅ?

អ៊ឹម ៖ ចាំ! នៅនេះរហូត ។

ថាយ ៖ ផ្ទះនេះឬនោះ?

អ៊ឹម ៖ នេះផ្ទះតូចនេះផ្ទះខ្ញុំឈរ ។

ថាយ ៖ តាំងមកនៅផ្ទះនេះ?

អ៊ឹម ៖ ផ្ទះហ្នឹងរហូត ឡើងបាក់បែកអស់ហើយពុកទេសសរពុកអីអស់ហើយ ។

ថាយ ៖ ហើយកាលពីមកនៅដំបូងមានមនុស្សមានអីច្រើនទេ?

អ៊ឹម ៖ មាននេះផ្ទះគ្រប់កន្លែងហ្នឹងឯង មកនៅក្រែល តាំងពីមកនៅគ្មានអ្នកណា ចេញទេ នៅហ្នឹងទាំងអស់ ។

ថាយ : នៅហ្នឹងទាំងអស់?

អ៊ុម : ចាំ!

ថាយ : អូ! គេចាប់បង្កើតភូមិនៅទីនេះហ្នឹង?

អ៊ុម : ចាំ!

ថាយ : គេមកដាក់យើងនៅហ្នឹងហ្នឹង?

អ៊ុម : គេឲ្យមកនៅ គាម៉ុកគាត់ឲ្យមកនៅនេះ ។

ថាយ : ចុះផ្ទះធំៗ ទើបនឹងសង់ក្រោយទេ?

អ៊ុម : ចាំ! ទើបសង់ក្រោយ ។

ថាយ : ពេលគាត់ឲ្យមកនៅហ្នឹងគេមានចែកដីចម្ការ ដីស្រែឲ្យទេ?

អ៊ុម : ចែក!

ថាយ : គេចែកឲ្យប៉ុន្មានដែរ?

អ៊ុម : ប៉ុន្តែខ្ញុំអត់មានបានដីស្រែនឹងគេទេ បានតែដីចម្ការ ។

ថាយ : បានតែដីចម្ការ! ហេតុអីមិនប្រាប់គេ?

អ៊ុម : ប្រធានភូមិ ប្រធានឃុំគេចែកគេអីឲ្យទៅណា ។

ថាយ : ចុះដីស្រែម៉េចអត់មាន?

អ៊ុម : ខ្ញុំអត់មានចំណែកហ្នឹងគេ ។

ថាយ : មីងគិតថាយើងអ្នកថ្មីក៏អី ឬដោយសារតែយើងជាអ្នកថ្មី?

អ៊ុម : ថ្មីដូចគ្នា ប៉ុន្តែដឹងម៉េចកាលប្រធានភូមិគេអត់គិតពីរឿងដីស្រែដីអី ។

ថាយ : ចុះដីចម្ការដីនៅណាទៅ?

អ៊ុម : នៅណោះក្រោយ ។

ថាយ : ជិតនេះដែរទេ?

អ៊ុម : ជិតនេះ ។

ថាយ : ប៉ុន្មានរយម៉ែ?

អ៊ុម : ប្រហែលប្រាំរយម៉ែត្រដឹងពីនេះទៅ ។

ថាយ : កាត់ព្រៃ?

អ៊ុម : វាលដែរតើ ។

ថាយ : ឥឡូវមីងកំពុងដាំអីដែរ?

អ៊ុម : ដាំដំឡូង ។

ថាយ ៖ ដំឡូងឈើ?

អ៊ុម ៖ ចា៎!

ថាយ ៖ ដំឡូងឈើឥឡូវកំពុងតែត្រូវប៉ាន់ គេឲ្យទំហំប៉ុន្មាន?

អ៊ុម ៖ មិនដឹងប៉ុន្មានមិនដែលវាស់ផង ។

ថាយ ៖ កាក់ឡូដំបូងមីងមានទេកាលណោះ ។

អ៊ុម ៖ អត់មានទេ អេអត់អីមានតែក្បាលគ្រាប់អី ។

ថាយ ៖ អូ៎! មានតែក្បាលគ្រាប់ទេដីឥឡូវអស់ហើយ?

អ៊ុម ៖ អស់ហើយអត់មានទេ ទើបនៅដុតភ្លើងក្បែរផ្ទះនិយាយពីផ្ទុះឡើងលឺងមាសចឹង ។

ថាយ ៖ ផ្ទុះដូចផាវក្ទុងៗចឹង?

អ៊ុម ៖ ដូចថាគ្រាប់បែកម៉េចចឹង ពុក្កាំងៗ ។

ថាយ ៖ ហ្នឹងពេលយើងប្រមូលដុតសម្រាមដុតអីហ្នឹង?

អ៊ុម ៖ ចា៎! ដុតសម្រាប់ជិតកន្លែងធ្វើរោងនៅហ្នឹង ។

ថាយ ៖ ទេមិញខ្ញុំសួរទំហំប៉ុន្មានមីង មានប្រាប់ទេ?

អ៊ុម ៖ អត់ ។

ថាយ ៖ ទំហំដីប៉ុន្មាន ដីដែលគេឲ្យហ្នឹង?

អ៊ុម ៖ ខ្ញុំអត់ដែលបានវាស់មើលទេមិនដឹងជាប៉ុន្មាន ។

ថាយ ៖ ក្បាល១អា ឬ២អា ប៉ុន្មានរយ ឬក៏៥០ម៉ែត ប្រហែលជាផ្ទះនោះដល់ណោះទេ ទទឹងវា ។

អ៊ុម ៖ ប្រហែល៥០-៦០ម៉ែតដឹងទទឹង ។

ថាយ ៖ ចុះបណ្តោយ?

អ៊ុម ៖ បណ្តោយជិត១០០ម៉ែត ។

ថាយ ៖ ចឹងទាំងកូនទាំងអីមកនៅនេះ?

អ៊ុម ៖ ចា៎! ទាំអស់ ។

ថាយ ៖ ចិញ្ចឹមរស់ដែរ?

អ៊ុម ៖ ចិញ្ចឹមរស់ ។

ថាយ ៖ បើទៅដល់ហើយ ទៅដល់គ្រាំកក់គេឲ្យ៤អាៗចង់កន្ទះហត្ថដែរ?

អ៊ុម ៖ ចង់កន្ទះហត្ថដែរ ប៉ុនដីវាអត់ល្អផងហ្នឹង ចុះបើកូនលើង៧នាក់ហើយនឹងដល់បានប្តី ទៅបែក
ប៉ុន្មានម្នាក់ទៅ មិនបាន១០ម៉ែតម្នាក់ផងនឹង ។

ថាយ ៖ ចុះបើឥឡូវនេះនៅប្រហែលជាកន្ទះហត្ថដែរហ្នឹង?

អ៊ុម ៖ នេះគេកាត់ដីបានផ្សេងៗទៀត ។

ថាយ ៖ អ៊ូ! កូនគេឲ្យផ្សេងៗទៀត?

អ៊ុម ៖ ចា៎! គេចាប់ដីគេក្រៅទៀត ។

ថាយ ៖ ចឹងនេះមកត្រឹមនេះមួយគ្រួសារប្ដីមីងដីនេះ កូនតាំងពីមកនេះគេមានផ្ទះមានអីចែកឲ្យដែរ?

អ៊ុម ៖ គេមានប្ដីមានអីចឹងទៅគេទៅតាំប្ដីគេចឹងទៅ ។

ថាយ ៖ ប៉ុន្មាននាក់ដែលបានដីផ្សេងទៀតនោះ?

អ៊ុម ៖ ៦នាក់ ។

ថាយ ៖ ៦នាក់ហ៎ា នៅតែអាពៅគេហ្នឹង?

អ៊ុម ៖ ចា៎! នៅតែមីពៅគេមួយ ។

ថាយ ៖ រួចមានគ្រួសារហើយ?

អ៊ុម ៖ ចា៎! មានអស់ហើយ ។

ថាយ ៖ ៦-៧នាក់សុទ្ធតែមានប្ដីដីទាំងអស់ ចឹងយើងធូរវាហើយ (ស្ដាប់មិនបាន) ព្រោះមានដី ៧នាក់បើម្នាក់មានដីទំហំប្រហែលៗមីងដែរ?

អ៊ុម ៖ ទំហំប្រហែលៗខ្ញុំដែរ ។

ថាយ ៖ ៦នាក់វាកន្លះហត្ថ អីបាន៣ហត្ថអីដែរ?

អ៊ុម ៖ ធូរជាងនៅស្រុក ។

ថាយ ៖ (ស្ដាប់មិនបាន) ។

អ៊ុម ៖ នៅជិតតាម៉ុកបាន តែប៉ុន្មានខែហ្នឹងដឹងហើយបែករហូតទៀត ។

ថាយ ៖ អ៊ូ! នៅជិតតាម៉ុកបានតែប៉ុន្មានខែហ្នឹង?

អ៊ុម ៖ ចា៎! គ្មានបាននៅជាប់ទេ ។

ថាយ ៖ អត់ដល់មួយឆ្នាំផងហ្នឹង ហើយចេញពីតាម៉ុកមកនេះមក?

អ៊ុម ៖ ចេញពីតាម៉ុករត់ទៅ ចេញពីរត់មកៗនៅនេះរហូត ។

ថាយ ៖ អ៊ូ! កាលផ្ទុះឆេះហើយហ្នឹងហ៎ា?

អ៊ុម ៖ ចា៎! តាម៉ុកឲ្យមកនៅនេះក៏មកនៅនេះមក ។

ថាយ ៖ (ស្ដាប់មិនបាន)?

អ៊ុម ៖ មកពីគៀសខ្លួនវិញធ្វើសមាហរណកម្មហ៎ា រត់មកដល់ហ្នឹង៦ឆ ។

ថាយ ៖ រត់កាលហ្នឹងម៉េចបានរត់?

អ៊ុម ៖ ចុះរត់ខ្វាចបាញ់គ្នា ទាហានគាម៉ុកហើយហ្នឹងទាហានពីក្នុងមកខ្វាចជួបគ្នាវ៉ៃគ្នាយើងរត់ទៅណា គេវ៉ៃគ្នា ។

ថាយ ៖ អូ៎! វ៉ៃគ្នាផ្ទៃក្នុងហេ៎?

អ៊ុម ៖ ផ្ទៃក្នុងអីកាលហ្នឹងទាហានខាង ហ៊ុន សែន ចូលមកចូលមកដ៏ហើយប្រពន្ធកូនអី មិននាំគ្នារត់ទៅ រត់ទៅនៅបាយតាប់ ។

ថាយ ៖ រត់ទៅណោះវិញ?

អ៊ុម ៖ ចា៎!

ថាយ ៖ ទៅក្នុងវិញ?

អ៊ុម ៖ លែងទៅលើហើយទៅក្នុងម្ដង ។

ថាយ ៖ តែគេអត់បានវ៉ៃណាហី កាលរត់ខ្វាចគេហ្នឹង?

អ៊ុម ៖ គេវ៉ៃតែគ្នាគេក្បែរជើងភ្នំក្បែរអីចឹងទៅណា ប៉ុន្តែយើងខ្វាចចេះតែរត់ទៅខ្វាចគ្រាប់ផ្លោងគ្រាប់កាំភ្លើងដៃហ្នឹង ហើយហ្នឹងកូនតូចៗ (ស្ដាប់មិន បាន) ។

ថាយ ៖ ចឹងមីងមានអីចង់បន្ថែមទៀតទេ(ស្ដាប់មិនបាន) ចឹងឥឡូវអត់ទៅយកដីនៅត្រាំកក់វិញទេ?

អ៊ុម ៖ អត់ទេ ។

ថាយ ៖ ឲ្យប្អូនថ្លៃឲ្យអីហើយ?

អ៊ុម ៖ ឲ្យទៅក្មួយ ។

ថាយ ៖ ក្មួយនៅហ្នឹងរហូត?

អ៊ុម ៖ ចា៎! នៅហ្នឹង ។

ថាយ ៖ អរគុណច្រើនណាមីង?

អ៊ុម ៖ ចា៎!

ថាយ ៖ ដែលបានផ្ដល់បទសម្ភាសន៍ បាទ!